# មេរៀនទី ១២៦៖ ពេត្រុសពន្យល់ពីការជឿលើព្រះយេស៊ូវ

១ ពេត្រុស ១៖៣-៩

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/s445KRv-cD4

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/bkDDMixZsxw

**គោលបំណង៖** ព្រះយេស៊ូវឱ្យយើងកើតជាថ្មី។

**ខគម្ពីរចងចាំ៖ ២ កូរិនថូស ៥៖១៧** *"បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ"*

**ចំរៀង** ( *យូធូបលីង* )៖

១.គឺជាការល្អដែលសរសើរព្រះ៖ https://youtu.be/Z91SULEHfho

២.Good News Club https://youtu.be/s3l_InHYe7o

៣.Good News https://youtu.be/rG4H_Te6q90

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត "ប្ដូរអាវរបស់អ្នក"




សម្ភារៈដែលត្រូវការ៖ អាវយឺតធំពីរ ឬបី

១. ចែកកុមារជាពីរឬ បីក្រុម

២. ឲ្យកុមារឈរជាជួរ ហើយជ្រើសរើសមេក្រុមម្នាក់មួយ

៣. គ្រូនឹងឲ្យអាវយឺតធំមួយទៅមេក្រុមនីមួយៗ ហើយមេក្រុមត្រូវពាក់អាវនោះ

៤. នៅពេលដែលគ្រូរាប់ ១ ២ ៣ មេក្រុមត្រូវចាប់ផ្ដើមដោះអាវយឺតនោះ ហើយឲ្យទៅកុមារបន្ទាប់។ ឲ្យកុមារបន្ទាប់បន្តពាក់ និងដោះអាវនោះ រហូតដល់កុមារចុងក្រោយ។

៥. ក្រុមណាដែលអាចប្ដូរអាវបានលឿនជាងគេក្រុមនោះជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ក៏ដូចជាការដែលប្ដូរអាវរបស់យើងអីចឹងដែរ ពួកយើងគឺចង់ផ្លាស់ប្ដូរដួងចិត្តរបស់យើងឲ្យទទួលជឿព្រះយេស៊ូវរបស់យើងវិញម្ដង។

## ៤. ការណែនាំមេរៀន

តើមានប្អូនប៉ុន្មាននាក់ស្គាល់សត្វដង្កូវខ្លះ? ដង្កូវគឺអាចផ្លាស់ប្ដូរខ្លួនទៅជាមេអំបៅដ៏ស្រស់ស្អាតបាន ការកើតជាថ្មី ប្រៀបបីដូចជាយើង បានផ្លាស់ប្ដូរដួងចិត្តដ៏អាក្រក់របស់ពួកយើង ទៅជាដួងចិត្តថ្មីស្រស់ស្អាតដូចមេអំបៅ តាមរយៈការទទួលជឿព្រះយេស៊ូវ។ ក៏ដូចគ្នាដែរថ្ងៃនេះ យើងនឹងរៀនអំពីការកើតជាថ្មីនៅក្នុងព្រះគ្រីស្ទ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវបានឱ្យជីវិតថ្មីមួយដល់អស់អ្នកណាដែលជឿដល់ទ្រង់។ ព្រះយេស៊ូវអាចធ្វើការនេះបានដោយព្រោះទ្រង់ជាព្រះ ហើយទ្រង់មានអំណាចលើសេចក្ដីស្លាប់។ ព្រះយេស៊ូវបានសុគត់ ហើយមានព្រះជន្មរស់

ឡើងវិញ, ហើយទ្រង់មានព្រះជន្មរស់រហូតដល់សព្វថ្ងៃ។

នៅពេលដែលយើងនិយាយថាព្រះយេស៊ូវបានផ្តល់ជីវិតថ្មីដល់យើង គឺមានន័យថាទ្រង់បានសង្គ្រោះយើងពីអំពើបាប។ ទ្រង់បានអត់ទោស និងលាងជំរះអំពើបាបរបស់យើង ព្រមទាំងធ្វើឱ្យយើងក្លាយជាមនុស្សថ្មីម្នាក់ថែមទៀតផង។ ព្រះគម្ពីរបានប្រាប់យើងថា យើងមិនត្រូវការធ្វើអ្វីដើម្បីឱ្យយើងបានទទួល នូវជីវិតថ្មីពីព្រះនោះទេ។ ព្រះប្រទានឱ្យយើងនូវជីវិតថ្មី នៅពេលដែលយើងជឿលើព្រះយេស៊ូវ នោះជាការជឿមួយដែលយើងហៅថាសេចក្តីជំនឿ។ យើងត្រូវតែជឿថា នៅពេលដែលយើងជាមនុស្សមានបាប ព្រះយេស៊ូវបានសុគត់នៅលើឈើឆ្កាងជំនួសយើង ហើយទ្រង់ក៏បានដកយកអំពើបាបគ្រប់យ៉ាងចេញពីយើងផងដែរ។ ក្រោយមកព្រះយេស៊ូវបានយកឈ្នះ លើសេចក្តីស្លាប់ ហើយទ្រង់មានព្រះជន្មរស់ឡើងវិញ ដូច្នេះហើយទើបទ្រង់អាចឱ្យយើងរាល់គ្នានូវជីវិតអស់កល្ប នៅឯឋានសួគ៌បាន! ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវតែងតែគង់ជាមួយ និងតម្រង់ផ្លូវយើង ហើយជួយឱ្យជ្រើសរើសផ្លូវដែលត្រឹមត្រូវ ដើម្បីក្លាយជាកូនប្រុស-ស្រីរបស់ព្រះអង្គ។

ពាក្យថាព្រះគុណ មានន័យថាគឺជាអ្វីមួយដែលព្រះបានប្រទានឱ្យយើង បើទោះបីជាយើងមិនស័ក្តសមនឹងទទួលវាក៏ដោយ នេះគឺដោយព្រោះទ្រង់ស្រឡាញ់យើង។ ការកើតជាថ្មី និងជីវិតថ្មីនៅក្នុងព្រះយេស៊ូវគឺប្រទានមកយើងតាមរយៈព្រះគុណ។ យើងមិនស័ក្តសមនឹងទទួលព្រះគុណនោះទេ ប៉ុន្តែព្រះបានប្រទានឱ្យយើងនៅពេលដែលយើងជឿទ្រង់ ដោយព្រោះទ្រង់ស្រឡាញ់យើង។

នៅពេលដែលយើងទទួលបាននូវការកើតជាថ្មីតាមរយៈសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវ យើងបានក្លាយជាផ្នែកមួយនៃគ្រួសាររបស់ព្រះ ហើយយើងទទួលបានអំណោយទាន និងអភ័យឯកសិទ្ធិដ៏អស្ចារ្យជាច្រើន។ យើងដឹងថា ពេលមានព្រះយេស៊ូវយើងនឹងមានសេចក្តីសង្ឃឹមដ៏ពិតប្រាកដសម្រាប់អនាគតរបស់យើង។ យើងក៏ដឹងផងដែរថា យើងនឹងទទួលនូវមរតកដែលមិនអាចបំផ្លាញបាន ហើយយើងដឹងថាអំណាចរបស់ព្រះបានការពារយើង។ យើងនឹងទទួលបានអំណរដ៏អស្ចារ្យ ហើយយើងនឹងអាចទៅនគរស្ថានសួគ៌ដើម្បីរស់នៅជាមួយព្រះជារៀងរហូត។

តើអ្នកមិនសប្បាយចិត្តទេឬដែលអ្នកបានក្លាយជាគ្រួសារនៃព្រះ តាមរយៈសេចក្តីជំនឿដែលយើងមានចំពោះទ្រង់។ សរសើរតម្កើងព្រះនាមព្រះយេស៊ូវដែលទ្រង់បានប្រទាននូវជីវិតថ្មីដល់យើង!

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវផ្តល់ជីវិតថ្មីដល់យើងដោយរបៀបណា?
*(ដោយព្រោះទ្រង់ជាព្រះ ហើយទ្រង់មានអំណាចលើសេចក្តីស្លាប់)*
២.តើអ្នកត្រូវធ្វើអ្វីដើម្បីឱ្យអ្នកមានសេចក្តីជំនឿទៅលើព្រះបាន?
*(ជឿថាព្រះយេស៊ូវបានស្លាប់ ជំនួសអំពើបាបរបស់យើង ហើយទ្រង់បានយកឈ្នះលើសេចក្តីស្លាប់ ដើម្បីឱ្យយើងមានជីវិត អស់កល្ប ហើយទ្រង់គង់ជាមួយយើងរហូតដល់សព្វថ្ងៃ)*
៣. តើពាក្យថាព្រះគុណមានន័យដូចម្តេច? *(ព្រះប្រទានឱ្យយើងនូវអ្វីដែលយើងមិនសមនឹងទទួល)*
៤. តើព្រះគុណអ្វីដែលព្រះបានប្រទានដល់យើង?
*(ការកើតជាថ្មីនៅក្នុងព្រះយេស៊ូវ នៅពេលដែលយើងជឿដល់ទ្រង់)*
៥. តើអ្នកសប្បាយចិត្តដែរឬទេនៅពេលដែលអ្នកបានក្លាយជាសមាជិកគ្រួសាររបស់ព្រះ?
*(សូមឱ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត “រាំជញ្ជូនប៉េងប៉ោង”

សម្ភារៈដែលត្រូវការ៖  ប៉េងប៉ោង




១. ឲ្យកុមារចាប់ដៃគូពីរៗនាក់
២. ក្រុមនីមួយៗត្រូវយកប៉េងប៉ោងម្នាក់មួយ
៣. ចំណុចចាប់ផ្តើម
ពួកគេត្រូវរាំឲ្យទៅដល់ចុងម្ខាងនៃថ្នាក់រៀនដោយរាំផង និង
ប្រើក្បាលរបស់ពួកគេព្យាយាមទប់ប៉េងបោងមិនឲ្យធ្លាក់ផង។( គ្រូត្រូវចាក់ភ្លេងឲ្យកុមាររាំ )
៤. ប្រសិនបើពួកគេធ្វើឲ្យបេងប៉ោងធ្លាក់នោះពួកគេនឹងចាញ់ល្បែងនេះ។
៥. ក្រុមណាដែលអាចរាំត្រឡប់មកដល់ទីចាប់ផ្តើមវិញបានមុនគេ ដោយមិនជ្រុះប៉េងប៉ោង នោះក្រុមរបស់ពួកគេជាអ្នកឈ្នះល្បែងនេះ ហើយក្រុមគេនឹងទទួលបានរង្វាន់។
៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ប៉េងប៉ោងមិនអាចត្រឡប់មកកាន់ទីចាប់ផ្តើមវិញដោយមិនមានកុមារបាននោះទេ។ ក៏ដូចគ្នានេះដែរ ពួកយើងគឺមិនអាចទទួលបានការសង្គ្រោះនិងទទួលបានជីវិតថ្មី ដោយមិនមានព្រះយេស៊ូវនោះទេ។

## ៨. ខគម្ពីរចងចាំ

**២ កូរិនថូស ៥៖១៧** *“បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មី ហើយអស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ។”*

## ៩. ហត្ថកម្ម “ព្រះយេស៊ូវបានផ្តល់ជីវិតថ្មីសម្រាប់យើង”

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្មនៅទំព័រខាងក្រោម,កូល័រទៀន,
ការបិត កន្ត្រៃ និងខ្មៅដៃ



១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់១សន្លឹក រួចឱ្យពួកគេផាត់ពណ៌
និងតុបតែងនៅខាងក្នុងនិងខាងក្រៅ រូបបេះដូង
២. ឱ្យកុមារកាត់រូបបេះដូង និង ខគម្ពីរចងចាំចេញ រួចឱ្យពួកគេបិតខគម្ពីរចងចាំនៅក្នុងបេះដូងនោះ
៣. ឱ្យកុមារអានខគម្ពីរចងចាំទាំងអស់គ្នា និងរំឭកពួកគេថា ព្រះយេស៊ូវបានផ្លាស់ប្រែពួកគេតាមរយៈសេចក្តីជំនឿរបស់ពួកគេចំពោះព្រះអង្គ។

## ១០. ចំរៀង *( ពីសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស )*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
ជ័យជំនះរបស់ព្រះយេស៊ូវលើសេចក្តីស្លាប់បាននាំមកនូវសេចក្តីសង្ឃឹមដែលមិនអាចផ្លាស់ប្តូរបានមកឱ្យពួកយើង។ តើសេចក្តីសង្ឃឹមលើព្រះយេស៊ូវមានឥទ្ធិពលយ៉ាងណាចំពោះសុភមង្គល ឬភាពមិនសប្បាយចិត្តរបស់អ្នក? តើវាអាចទៅរួចដែរឬទេដែលយើងមានសង្ឃឹមហើយ ប៉ុន្តែមិនអាចសប្បាយចិត្តបាន? ការដែលមានសេចក្តីសង្ឃឹមមិនមែនមានន័យថាយើងនឹងមានជីវិតសប្បាយរីករាយរហូតនោះទេ ប៉ុន្តែវាជួយឱ្យយើងអាចផ្លាស់ប្តូរការគិតនៅក្នុងជីវិតបាន។ សូមឱ្យទ្រង់បានបង្ហាញអ្នកពីរបៀបដែលអ្នកឆ្លុះបញ្ចាំងពីសេក្តីសង្ឃឹមរបស់អ្នកចំពោះព្រះយេស៊ូវនៅក្នុងជីវិតរបស់អ្នក? សូមអរព្រះគុណទ្រង់សម្រាប់ការស្តារព្រលឹងរបស់យើងឡើងវិញ, ដែលបានផ្តល់ឱ្យយើងនូវអំណោយដ៏ពិត និងប្រទានឱ្យយើង នូវសេចក្តីសង្ឃឹមជារៀងរហូតផងដែរ។

# ព្រះយេស៊ូវបានផ្តល់ជីវិតថ្មីសម្រាប់យើង



**២ កូរិនថូស ៥៖១៧** *“បានជាបើ
អ្នកណានៅក្នុងព្រះគ្រីស្ទ នោះ
ឈ្មោះថាបានកើតជាថ្មី ហើយ
អស់ទាំងសេចក្ដី ចាស់បានកន្លង
បាត់ទៅ មើលគ្រប់ទាំងអស់បាន
ត្រឡប់ជាថ្មីវិញ។”*


# ព្រះយេស៊ូវបានផ្តល់ជីវិតថ្មីសម្រាប់យើង





**២ កូរិនថូស ៥៖១៧** *“បានជាបើ
អ្នកណានៅក្នុងព្រះគ្រីស្ទនោះ
ឈ្មោះថាបានកើតជាថ្មី ហើយ
អស់ទាំងសេចក្ដី ចាស់បានកន្លង
បាត់ទៅ មើលគ្រប់ទាំងអស់បាន
ត្រឡប់ជាថ្មីវិញ។”*